00754335

E141

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

សាធារណៈ / Public
13/12/2011

~~Confidential / Confidentiel~~

# អង្គជំនុំជម្រះសាលាដំបូង

**ជូនចំពោះ៖** ភាគីទាំងអស់នៅក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 22 / 11 / 2011
ម៉ោង (Time/Heure): 14:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

**ពី៖** លោកស្រី Susan Lamb
មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់នៃអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោកប្រធានចៅក្រម និងចៅក្រម អង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១

នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១ តាមរយៈសារអេឡិចត្រូនិក(email) ភាគីទាំងអស់ ត្រូវបានស្នើសុំឱ្យលើកឡើងលក្ខណៈមិនផ្លូវការជាមួយនឹងលោកស្រី Susan Lamb មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់នៃអង្គជំនុំជម្រះសាលាដំបូង នៅត្រឹមថ្ងៃ អង្គារ ទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ចំពោះបញ្ហានៅសេសសល់ ដែលគាគីផ្សេងៗចាត់ទុកថាតម្រូវឱ្យមានដំណោះស្រាយ និងអាចរារាំងដល់ប្រសិទ្ធផលនៃដំណើរការសវនាការដំណាក់កាលដំបូងលើអង្គសេចក្តីនៅក្នុងសំណុំរឿង ០០២ (ធ្វើឡើងនៅថ្ងៃទី ៥ ដល់ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១)។ អនុស្សរណៈនេះដោះស្រាយបញ្ហាការឆ្លើយតបដូចមានខាងក្រោមដែលទទួលបានពីភាគីផ្សេងៗចាប់ពីពេលនោះមក បូករួមជាមួយនឹងការដាក់ឯកសារផ្សេងៗទៀតដែលទទួលបានរហូតមកដល់សព្វថ្ងៃនេះ។

- សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឱ្យមានការប្រជុំមួយស្តីពីការរៀបចំសវនាការ និងការប្រជុំទៀងទាត់នានាស្តីពីស្ថានភាពសវនាការសម្រាប់សំណុំរឿង ០០២ ចុះថ្ងៃទី ២១ ខែ

Original EN: 00754053-00754058

តុលា ឆ្នាំ ២០១១ (ឯកសារ E132) (គាំទ្រដោយសហមេធាវីរបស់ អៀង សារី)(ឯកសារ E132/1))

- លិខិតពីសហមេធាវីរបស់ អៀង សារី ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១ (ឯកសារ E132/1.3)(បានឆ្លើយតបដោយផ្នែកខ្លះមាននៅក្នុងឯកសារ E124/7 ឯកសារ E131/1 និងតាមរយៈសារអេឡិចត្រូនិកពីមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ជូនចំពោះភាគីទាំងអស់ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១) លិខិតពីសហមេធាវីរបស់ អៀង សារី ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១១ (ឯកសារ E132/1.2) និងចុះថ្ងៃទី ១ ខែ វិច្ឆកា ឆ្នាំ ២០១១
- លិខិតចម្លងមួយច្បាប់ទុកជាមុនជូនចំពោះមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ ពីសហព្រះរាជអាជ្ញារង ចុះថ្ងៃទី ១ ខែ វិច្ឆកា ឆ្នាំ ២០១១ និង
- សំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ស្នើសុំឱ្យមានកិច្ចប្រជុំរៀបចំសវនាការ និងការប្រជុំទៀងទាត់ស្ដីពីស្ថានភាពសវនាការសម្រាប់សំណុំរឿង ០០២ និងស្នើសុំការបញ្ជាក់ស្ដីពីការកំណត់ពេលវេលា និងការរៀបចំសវនាការ ចុះថ្ងៃទី ២ ខែ វិច្ឆកា ឆ្នាំ ២០១១ (ឯកសារ E132/2)

*ព័ត៌មានទូទៅ*

រហូតមកដល់ពេលនេះ ព័ត៌មានមួយចំនួនក្នុងចំណោមព័ត៌មានដែលភាគីផ្សេងៗបានស្នើសុំ ត្រូវបានផ្ដល់ជូនដូចមាននៅក្នុងអនុស្សារណៈ និងសេចក្ដីសម្រេចនាពេលថ្មីៗនេះរបស់អង្គជំនុំជម្រះសាលាដំបូង (ឧទាហរណ៍ សូមមើល ឯកសារ E131 ឯកសារ E101/5 និង ឯកសារ E124/7) ជាពិសេសដោះស្រាយបញ្ហាសវនាការដែលត្រូវធ្វើឡើងរវាងថ្ងៃទី ៥ ដល់ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១ (ឯកសារ E131/1 រួមទាំងឧបសម្ពន្ធសម្ងាត់ ក និង ខ (ឯកសារ E131/1.1 និង ឯកសារ E131/2 តាមលំដាប់រៀងគ្នា))។ នៅថ្ងៃទី ១៥ ខែ វិច្ឆកា ឆ្នាំ ២០១១ (ឯកសារ E131/4/1) អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់សហមេធាវីនាំមុខស្នើសុំធ្វើការកត់សម្គាល់ត្រួសៗ ជំនួសមុខឱ្យដើមបណ្ដឹងរដ្ឋប្បវេណី បន្ទាប់ពីសហព្រះរាជអាជ្ញាធ្វើការសន្និដ្ឋានចោទប្រកាន់ (ឯកសារ E131/4)។

ដោយលើកលែងថ្ងៃឈប់សម្រាក ដំណើរការនីតិវិធីសវនាការ នឹងប្រព្រឹត្តទៅតាមធម្មតា ពីថ្ងៃ ចន្ទ ដល់ថ្ងៃ ព្រហស្បតិ៍ (ដែលរាប់បញ្ចូលចំណុចនានាដែលបានលើកឡើង)ពីម៉ោង ៩ ព្រឹក ដល់ម៉ោង ៤ រសៀល។

E141

~~បម្ងាត់ / Confidential / Confidentiel~~

ព័ត៌មានបន្ថែមទៀតទាក់ទិននឹងសវនាការជាបន្តបន្ទាប់នៅក្នុងសំណុំរឿង ០០២ និង០១ ព្រមទាំងសវនាការលើកក្រោយៗទៀត នឹងជម្រាបជូនភាគីទាំងអស់ក្នុងថិរវេលាសមស្រប។

*ដីកាបង្គាប់សម្រាប់ការសួរដេញដោលលើប្រធានបទ*

សំណុំរឿង ០០២ ឥឡូវនេះត្រូវបានបំបែកជាផ្នែកៗ ហើយការសួរដេញដោលនៅក្នុងសវនាការត្រូវអនុវត្តតាមប្រធានបទដែលបានបង្ហាញជូនភាគីទាំងអស់តាមរយៈឧបសម្ព័ន្ធ ឯកសារ E124/7 ដើម្បីធានាឱ្យមានលំដាប់លំដោយត្រឹមត្រូវក្នុងការសួរដេញដោលជនជាប់ចោទ សាក្សី អ្នកជំនាញ និងភាគីដើមបណ្តឹងរដ្ឋប្បវេណី។

ការសួរចម្លើយជនជាប់ចោទនឹងចាប់ផ្តើមនៅក្នុងសវនាការផ្នែកដំបូងនៅក្នុងសំណុំរឿង ០០២/០១ ស្តីពីសាវតារប្រវត្តិ។ ដូច្នេះ កថាខណ្ឌ ១៨-៣២ នៃដីកាដំណោះស្រាយ នឹងត្រូវបានអាន ហើយទាក់ទិននឹងជនជាប់ចោទនីមួយៗ កថាខណ្ឌពាក់ព័ន្ធបន្ថែមទៀតនឹងត្រូវអានផងដែរ ៖

នួន ជា ៖ កថាខណ្ឌ ៨៦២-៨៦៨ និង កថាខណ្ឌ ១៥៧៧-១៥៨០

អៀង សារី ៖ កថាខណ្ឌ ៩៩៤-១០០០ កថាខណ្ឌ ១០៩១ និង កថាខណ្ឌ ១៥៨៥-១៥៨៨

ខៀវ សំផន ៖ កថាខណ្ឌ ១១២៦-១១៣០ និង កថាខណ្ឌ ១៥៩៨-១៦០០

អង្គជំនុំជម្រះ បានធ្វើការកត់សម្គាល់ទៅលើសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំការបញ្ជាក់ពីវិសាលភាពនៃសវនាការដំណាក់កាលដំបូង ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ឯកសារ E124/9)។ ទាក់ទិននឹងការសួរដេញដោលទៅលើគោលនយោបាយផ្សេងៗក្រៅពីគោលនយោបាយដែលជាប់ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដោយបង្ខំ គោលបំណងនៃការបញ្ចូលការលើកឡើង គោលនយោបាយផ្សេងៗទាំងនោះនៅក្នុងសវនាការដំណាក់កាលដំបូង គឺដើម្បីឱ្យមានលទ្ធភាពបង្ហាញពីរបៀបដែលគោលនយោបាយ[នៃការជម្លៀសប្រជាជនដោយបង្ខំ]ត្រូវបានបង្កើតឡើង។ ដូច្នេះ អ្វីដែលរំពឹងទុកគឺការបង្ហាញជាទូទៅពីគោលនយោបាយទាំងប្រាំ ទោះបីជាបញ្ហាជាក់ស្តែងសម្រាប់សួរដេញដោល នៅក្នុងសវនាការដំណាក់ដំបូងត្រូវបានកម្រិតនៅត្រឹមការជម្លៀសប្រជាជនដោយបង្ខំ (ដំណាក់កាលទី ១ និង ទី២) យ៉ាងណាក៏ដោយ។ ដូច្នេះ នឹងមិនមានការពិនិត្យលើការអនុវត្តគោលនយោបាយផ្សេងៗក្រៅពីគោលនយោបាយដែលពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដោយបង្ខំ (ដំណាក់កាលទី ១ និង ទី២) ឡើយ។

~~សម្ងាត់ / Confidential / Confidentiel~~

កថាខណ្ឌដែលបានបញ្ជាក់ខាងលើនៃដីកាដំណោះស្រាយ ទាក់ទិននឹងសវនាការដំណាក់កាលដំបូងគឺពាក់ព័ន្ធនឹងសាវតារប្រវត្តិ ហើយមិនពាក់ព័ន្ធនឹងគោលនយោបាយទាំងប្រាំឡើយ។ ប្រសិនបើមានការពិចារណាឃើញថា ការអនុវត្តគោនយោបាយទាំងនេះបានចាប់ផ្តើមមុនខែ មេសា ឆ្នាំ ១៩៧៥ នោះសំណួរស្តីពីបញ្ហាទាំងនេះត្រូវរំពឹងថាអាចកើតឡើងក្នុងសវនាការដំណាក់ដំបូងនេះដោយចៃដន្យប៉ុណ្ណោះ។

សរុបមក ភាគីទាំងអស់ត្រូវបានស្នើសុំឱ្យផ្តោតយកចិត្តទុកដាក់សួរសំណួរឱ្យបានលម្អិតទៅលើភាគីដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីនីមួយៗចំពោះអង្គហេតុទាក់ទិននឹងសវនាការដំណាក់ដំបូងនេះ។ ការសួរដេញដោលលើប្រធានបទផ្សេងៗដែលនឹងត្រូវបញ្ចូលនៅក្នុងសវនាការលើកក្រោយៗ មិនត្រូវបានអនុញ្ញាតឡើយ។ សេចក្តីណែនាំបន្ថែមទៀតនឹងផ្តល់ជូនភាគីទាំងអស់ក្នុងដំណើរពេលដែលសវនាការដំណើរការទៅមុខប្រសិនចាំបាច់។

*ការផ្តល់ជូនសាធារណជននូវព័ត៌មានចេញពីដីកាដំណោះស្រាយ*

មុនពេលការសួរដេញដោលក្រោមប្រធានបទនីមួយៗបានចាប់ផ្តើម កថាខណ្ឌជាប់ពាក់ព័ន្ធនៃដីកាដំណោះស្រាយត្រូវអានជូនជាសាធារណៈដោយក្រឡាបញ្ជី។ លើកលែងតែមានដីកាបង្គាប់ផ្ទុយ ឯកសារ ឬប្រភពផ្សេងទៀតដែលបានលើកយោងនៅចុងទំព័រនៃកថាខណ្ឌនីមួយៗនៅក្នុងឯកសារទាំងនោះត្រូវកំណត់ឱ្យយកមកដាក់នៅចំពោះមុខអង្គជំនុំជម្រះ (វិធានផ្ទៃក្នុង ៨៧(២) និង (៣)) ដោយពុំចាំបាច់មានដីកាបង្គាប់បន្ថែមទៀតឡើយ។

*ដំណើរការនីតិវិធី*

អនុលោមតាមវិធានផ្ទៃក្នុង៩០ ប្រធានអង្គជំនុំជម្រះអាចអនុញ្ញាតឱ្យចៅក្រមអង្គជំនុំជម្រះសាលាដំបូងសួរចម្លើយជនជាប់ចោទ សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញរូបណាម្នាក់ បន្ទាប់មកចៅក្រមនោះនឹងមានការទទួលខុសត្រូវសំខាន់ក្នុងការសួរចម្លើយជននោះ។ បន្ថែមពីលើនេះ ប្រធានអង្គជំនុំជម្រះតាមអនុស្សរណៈ អាចចាត់តាំងសហព្រះរាជអាជ្ញា សហមេធាវីការពារជនជាប់ចោទនីមួយៗ ឬសហមេធាវីនាំមុខ ឱ្យទទួលខុសត្រូវសំខាន់ក្នុងការសួរដេញដោលសាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីជាក់លាក់ណាមួយ។ ការចាត់តាំងបែបនេះត្រូវជូនដំណឹងដល់ភាគីជាប់ពាក់ព័ន្ធ មុនពេលដែល

សាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីនោះផ្តល់សក្ខីកម្ម ដើម្បីផ្តល់លទ្ធភាពដល់ភាគីនោះឲ្យត្រៀមរៀបចំបានគ្រប់គ្រាន់។

*ការសួរចម្លើយជនជាប់ចោទ*

អនុលោមតាមវិធានផ្ទៃក្នុង៩០ ប្រធានអង្គជំនុំជម្រះ ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ភាគីទាំងអស់ និងមេធាវី មានសិទ្ធិសួរជនជាប់ចោទ។ ជនជាប់ចោទ អាចបដិសេធមិនឆ្លើយសំណួរ (វិធានផ្ទៃក្នុង ២១ (១) ឃ)។

ក្រោយពីចៅក្រមអង្គជំនុំជម្រះសាលាដំបូងដែលបានចាត់តាំងដោយប្រធានអង្គជំនុំជម្រះ ឲ្យធ្វើការសួរដេញដោលជនជាប់ចោទនីមួយៗ បានបញ្ចប់ការសួរដេញដោលនេះ សិទ្ធិសួរដេញដោលបន្ទាប់នឹងផ្តល់ជូនដល់ចៅក្រមផ្សេងទៀត និងបន្ទាប់មកភាគីទាំងអស់តាមលំដាប់លំដោយគឺ៖ សហព្រះរាជអាជ្ញា សហមេធាវីនាំមុខ និងសហមេធាវីការពារជនជាប់ចោទ ដូចតាមលំដាប់លំដោយដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (នួន ជា, អៀង សារី និង ខៀវ សំផន) ដោយមេធាវីតំណាងជនជាប់ចោទដែលត្រូវបានសួរដេញដោល មានឱកាសចុងក្រោយដើម្បីសួរដេញដោល។

ប្រសិនបើមិនមានសេចក្តីសម្រេចផ្ទុយ អង្គជំនុំជម្រះនឹងសួរជនជាប់ចោទនីមួយៗ តាមលំដាប់លំដោយដូចបានកំណត់នៅក្នុងដីការបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ E101/5)។ អង្គជំនុំជម្រះសាលាដំបូងរក្សាសិទ្ធិនៅពេលវេលាពាក់ព័ន្ធណាមួយ ក្នុងការដាក់សំណួរសួរជនចាប់ចោទ ដើម្បីផ្តល់ឱកាសឲ្យបញ្ចេញមតិយោបល់។ បន្ទាប់មក ភាគីទាំងអស់នឹងត្រូវបានផ្តល់នូវឱកាសឲ្យសួរសំណួរ។ សំណួរដែលត្រូវសួរជនជាប់ចោទ នៅថ្ងៃទី ៥ ខែ ធ្នូ និងថ្ងៃបន្តបន្ទាប់ទៀត នឹងចាប់ផ្តើមជាមួយនឹងសំណួរទាក់ទិងនឹងសាវតារប្រវត្តិ(ខាងលើ)។ ក្នុងករណីណាក៏ដោយ ក៏ការចោទសួរនេះត្រូវកម្រិតនៅត្រឹមប្រធានបទទាក់ទិននឹងវិសាលភាពនៃសំណុំរឿង ០០២/០១ តែប៉ុណ្ណោះ។

អង្គជំនុំជម្រះធ្វើការកត់សម្គាល់លើការលើកឡើងរបស់ សហមេធាវីរបស់ អៀង សារី ដែលបានបង្ហាញថា ជនជាប់ចោទ អៀង សារី នឹងមិនផ្តល់សក្ខីកម្មទាក់ទិននឹងសំណុំរឿង ០០២ (ឯកសារ E101/4 និង E101/4.1)។ អង្គជំនុំជម្រះ សូមអរគុណដល់សហមេធាវីរបស់ អៀង សារី ចំពោះការបង្ហាញនេះ ដែលជួយអង្គជំនុំជម្រះ និងភាគីផ្សេងទៀតក្នុងការរៀបចំផែនការសម្រាប់ដំណាក់កាលដំបូងនៃ

សវនាការ។ ការបង្ហាញផ្សេងៗពីសហមេធាវីរបស់ នួន ជា និង ខៀវ សំផន នឹងជួយថែមទៀតដល់អង្គជំនុំជម្រះ និងភាគីផ្សេងទៀតក្នុងការប៉ាន់ស្មានថាតើការចោទសួរសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីដំបូងៗនៅក្នុងសវនាការ អាចនឹងចាប់ផ្ដើមបានលឿនប៉ុណ្ណា ហើយអាចឱ្យពួកគាត់ត្រៀមរៀបចំបានសមស្រប។

*ការស្ដាប់ចម្លើយសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី*

បន្ទាប់ពីការចោទសួរលើជនជាប់ចោទទាំងអស់បានបញ្ចប់ស្ដីពីសាវតារប្រវត្តិ(ខាងលើ) អង្គជំនុំជម្រះ និងភាគីទាំងអស់ត្រូវសួរដេញដោលសាក្សី និងអ្នកជំនាញទាក់ទិននឹងប្រធានបទនោះ។ ដើម្បីចៀសវាងស្នើសុំឱ្យសាក្សី ឬអ្នកជំនាញ ត្រឡប់មកចូលរួមម្ដងទៀតនៅក្នុងសំណុំរឿង ០០២/០១ សាក្សី ឬអ្នកជំនាញគួរត្រូវបានសួរដេញដោលលើប្រធានបទទាំងអស់នៅក្នុងសំណុំរឿង ០០២/០១ ដែលពួកគាត់មានលទ្ធភាពដឹង ដោយសួរដេញដោលតាមលំដាប់លំដោយនៃប្រធានបទ(ដូចបានកំណត់នៅក្នុងឧបសម្ព័ន្ធ E124/7.1) ដែលណែនាំអំពីដំណើរការនីតិវិធីសួរដេញដោលនេះ។

ក្នុងករណីដែលប្រធានអង្គជំនុំជម្រះ បានចាត់តាំងការទទួលខុសត្រូវសំខាន់ក្នុងការសួរសាក្សី អ្នកជំនាញ ឬដើមបណ្ដឹងរដ្ឋប្បវេណី ប្រគល់ជូនសហព្រះរាជអាជ្ញា សហមេធាវីការពារជាប់ចាប់ចោទ ឬសហមេធាវីនាំមុខ នោះចៅក្រមនឹងខទ្វេសនាមពីសាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណីនោះ ហើយធ្វើការចោទសួរជាបឋមមុនពេលដែលអញ្ជើញភាគីនោះបន្តការសួរដេញដោល។ ការអនុវត្តដូចគ្នានេះនឹងត្រូវអនុវត្តសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់។ វាជាលក្ខណៈ ល្អប្រសើរដែលត្រូវណែនាំដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការផ្ដល់ចម្លើយ ដោយស្នើសុំដើមបណ្ដឹងរដ្ឋប្បវេណីនីមួយៗឱ្យផ្ដោតយកចិត្តទុកដាក់លើប្រធានបទតាមលំដាប់លំដោយដូចបានកំណត់ខាងលើ ដែលចុងបញ្ចប់នៃការផ្ដល់ចម្លើយលើកឡើងពីព្យសនកម្មដែលពួកគាត់បានទទួលរង។

*ដីកាកោះហៅសាក្សីសម្រាប់សវនាការដំណាក់កាលដំបូង*

អង្គជំនុំជម្រះ នឹងស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី ដូចមាននៅក្នុងឧបសម្ព័ន្ធ ខ (E131/1.2)នៅក្នុងដីកាកោះហៅ ដែលត្រូវជូនដំណឹងក្នុងពេលឆាប់ៗខាងមុខនេះ។

អង្គភាពគាំពារសាក្សី និងអ្នកជំនាញ (WESU) បានជម្រាបដល់អង្គជំនុំជម្រះថា ក្នុងចំណោមសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៨ រូបដូចមាននៅក្នុងឧបសម្ព័ន្ធ ខ (E131/1.2) សាក្សីលេខកូដ

TCW-297 បានទទួលមរណភាពហើយ[1]។ អង្គភាព WESU បានទាក់ទងសាក្សីដែលនៅសេសសល់ទាំងអស់ដូចមាននៅក្នុងឧបសម្ពន្ធសម្ងាត់ ខ (E131/1.2)។ ការស្តាប់ចម្លើយសក្ខីកម្មដែលនឹងត្រូវធ្វើឡើងដោយសាក្សីលេខកូដTCW-395 តាមរយៈបណ្តាញវីដេអូ កំពុងស្ថិតនៅក្រោមការពិចារណានាពេលបច្ចុប្បន្ននេះ។ ភាគីទាំងអស់នឹងត្រូវជូនដំណឹងបន្ថែមទៀតក្នុងថិរវេលាសមស្រប។

បុគ្គលនៅក្នុងឧបសម្ពន្ធសម្ងាត់ ខ (E131/1.2)ដែលអង្គជំនុំជម្រះមិនអាចស្តាប់ចម្លើយនៅមុនថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១ នឹងត្រូវស្តាប់ចម្លើយនៅពេលដែលដំណើរការនីតិវិធីចាប់ផ្តើមឡើងវិញនៅថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០១២ និងនៅពេលបន្តបន្ទាប់ទៀត។ ក្នុងថិរវេលាសមស្រប អង្គជំនុំជម្រះនឹងផ្តល់ជូនភាគីទាំងអស់នូវបញ្ជីសាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីជាបន្តបន្ទាប់ដែលត្រូវស្តាប់ចម្លើយ។

សាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវចោទសួរដោយភាគីផ្សេងៗតាម លំដាប់លំដោយ(ខាងលើ)ដូចជនជាប់ចោទដែរ។ ដោយហេតុថា សាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់មិនមែនសុទ្ធមានភាពជាប់ពាក់ព័ន្ធប៉ុនគ្នានៅក្នុងសវនាការឡើយ ទើបអង្គជំនុំជម្រះធ្វើការពិចារណាថាមិនសមស្របឡើយដែលត្រូវចេញពេលវេលាកំណត់សម្រាប់ភាគីទាំងអស់ក្នុងការសួរដេញដោលក្នុងដំណាក់កាលនេះ។ ទោះបីយ៉ាងណា ភាគីទាំងអស់ត្រូវបានរំពឹងថានឹងកំណត់សំណួររបស់ខ្លួននៅត្រឹមផ្នែកដែលពាក់ព័ន្ធ ហើយសហមេធាវីការពារជនជាប់ចោទ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវចៀសវាងសួរសំណួរដដែលៗ។ ពេលវេលាកំណត់នឹងត្រូវធ្វើឡើងដោយអង្គជំនុំជម្រះ ក្នុងករណីយល់ឃើញថាចាំបាច់។

*ការត្រៀមរៀបចំរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ*

អង្គជំនុំជម្រះយល់ស្របថា ប្រសិទ្ធផលនៃដំណើរការនីតិវិធី អាចបង្កើនបានប្រសិនបើមុនពេលផ្តល់សក្ខីកម្ម សាក្សីត្រូវបានផ្តល់ឱកាសឲ្យរំលឹកពីការចងចាំរបស់ពួកគេ ដោយពិនិត្យមើលចម្លើយមុនៗរបស់ពួកគេ។ អង្គជំនុំជម្រះនឹងធានាថា អង្គភាព WESU ទទួលបាននូវចម្លើយមុនៗរបស់សាក្សីម្នាក់ៗដើម្បីឲ្យសាក្សីអាចពិនិត្យមើលចម្លើយរបស់ពួកគេមុនពេលផ្តល់សក្ខីកម្ម។ អង្គជំនុំជម្រះ សូមពឹងអាស្រ័យ

---

[១] ទោះបីជាមិនត្រូវបានកោះហៅឲ្យផ្តល់សក្ខីកម្មនៅក្នុងសវនាការក៏ដោយ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ បានជម្រាបជូនបន្ថែមថា សាក្សីលេខសម្គាល់ TCW-604 ក៏បានទទួលមរណភាពផងដែរ ដោយសាក្សីរូបនេះមានឈ្មោះនៅក្នុងឧបសម្ពន្ធ ក E131/1 ដូច្នេះពាក់ព័ន្ធនឹងសវនាការដំណាក់កាលលើកក្រោយៗនៅក្នុងសំណុំរឿង ០០២/០០១។

លើសហមេធាវីនាំមុខឲ្យជួយធានាថា ដើម្បីផលប្រយោជន៍ឲ្យដំណើរការនីតិវិធីបានលឿន ដើមបណ្ដឹងរដ្ឋប្បវេណីនឹងកំណត់ព័ត៌មានដែលត្រូវផ្ដល់ជូនអង្គជំនុំជម្រះ ឲ្យនៅក្នុងកម្រិតមួយដែលពាក់ព័ន្ធសំណុំរឿង ០០២/០១ ។ សេចក្ដីណែនាំអំពីតម្រូវការទៅលើវិសាលភាពនៃសក្ខីកម្មរបស់អ្នកជំនាញទាក់ទិននឹងសំណុំរឿង ០០២/០១ នឹងត្រូវផ្ដល់ជូនដោយអង្គជំនុំជម្រះ ក្នុងករណីយល់ឃើញថាចាំបាច់។

*វិធានការទាក់ទិននឹងការធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង*

អង្គភាព WESU បានជូនដំណឹងថា ទម្រង់បែបបទស្រដៀងគ្នាដែលបានប្រើប្រាស់នៅក្នុងសំណុំរឿង ០០១ ទាក់ទិននឹងសិទ្ធិការពារមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង នឹងមាន ហើយក៏យកមកប្រើប្រាស់នៅក្នុងសំណុំរឿង ០០២ ផងដែរ។

*ការជំទាស់ទៅលើឯកសារ*

ពេលកំណត់ និងទម្រង់បែបបទដើម្បីឲ្យការជំទាស់ទៅលើឯកសារទទួលយកបាននៅក្នុងសវនាការដំណាក់កាលដំបូងនេះមានបង្ហាញនៅក្នុងឯកសារ E131/1 ។ ឯកសារទាំងនេះត្រូវបានបង្ហាញនាពេលថ្មីៗនេះនៅក្នុងការដាក់ឯកសារផ្សេងៗរបស់ភាគីផ្សេងៗបាន ទាន់ពេលកំណត់ ឬមុនពេលកំណត់គឺថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១១។ តាមរយៈសារអេឡិចត្រូនិកជូនភាគីទាំងអស់នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០១១ ពេលកំណត់សម្រាប់ការដាក់ឯកសារទាក់ទិននឹងបុគ្គលដែលអាចត្រូវកោះហៅចូលរួម ក្នុងសវនាការដំណាក់កាលដំបូង ត្រូវបានអង្គជំនុំជម្រះពន្យារពេលរហូតដល់ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១១។ ភាគីមួយចំនួនបានប្រើប្រាស់ពេលវេលាបន្ថែមនេះដើម្បីជាប្រយោជន៍។ ដោយហេតុថា ថ្ងៃទី ១១ វិច្ឆិកា នេះគឺជាថ្ងៃឈប់សម្រាក ទើបពេលវេលាកំណត់យកនៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ វិញ។ អង្គជំនុំជម្រះនឹងធ្វើសេចក្ដីសម្រេចលើបណ្ដឹងជំទាស់ទាំងនេះ និងឯកសារដែលបានដាក់មុននេះទាក់ទិននឹងសវនាការដំណាក់កាលដំបូងនេះ ក្នុងថិរវេលាសមស្រប។

*ការលើកយោងឯកសារក្នុងអំឡុងដំណើរការនីតិវិធី*

អង្គជំនុំជម្រះ ធ្វើការកត់សម្គាល់លើសំណើរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ឯកសារ E136 )ស្នើឲ្យបង្កើតប្រព័ន្ធមួយប្រកបដោយប្រសិទ្ធផលសម្រាប់ទទួលឯកសារភស្ដុតាងក្នុងពេលដំណើរការសវនាការ។ អនុលោមតាមការអនុវត្តដែលត្រូវបានទទួលយកនៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសូមធ្វើការបញ្ជាក់ថាភាគីទាំងអស់នឹងត្រូវបានអនុញ្ញាតឲ្យដាក់ឯកសារផ្ទាល់ជូនអង្គជំនុំជម្រះ

E141



បន្ថែមពីលើការដាក់ឯកសារតាមរយៈសាក្សី។ នៅក្នុងសំណុំរឿង ០០១ ការទទួលយកឯកសារដែលមិនទាក់ទិននឹងសាក្សីជាក់លាក់ណាមួយ បានធ្វើឡើងនៅចុងបញ្ចប់នៃការបង្ហាញភស្តុតាង។ អង្គជំនុំជម្រះនឹងផ្តល់សេចក្តីណែនាំដល់ភាគីទាំងអស់អំពីការកំណត់ពេលវេលានៃការទទួលយកឯកសារទាំងនេះ ក្នុងថិរវេលាសមស្រប។ ក៏ដូចការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០១ ដែរ ឯកសារនៅក្នុងបញ្ជីឯកសាររបស់ភាគីផ្សេងៗដែលមិនមានការជំទាស់ពីភាគីជំទាស់ណាមួយត្រូវចាត់ទុកថា ទទួលយកជាភស្តុតាងដោយគ្មានការស៊ើបសួរថែមទៀតឡើយ។ ករណីនេះអាចកើតឡើងបន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើការជំទាស់ទាំងអស់ដែលបានដាក់នាពេលថ្មីៗ និងការជំទាស់ទាំងអស់ដែលជាប់ពាក់ព័ន្ធ(ខាងលើ)។ នៅពេលដែលលើកយោងទៅលើឯកសារក្នុងសំណុំរឿងក្នុងដំណើរការនីតិវិធី អង្គជំនុំជម្រះ និងភាគីទាំងអស់ត្រូវប្រើប្រាស់លេខយោងនៃការដាក់ឯកសារ (ឧទាហរណ៍ E124) ហើយប្រសិនបើគ្រាន់តែលើកយោងទៅលើផ្នែកជាក់លាក់ ឬផ្នែកកំណត់ណាមួយនៃឯកសារនេះ ក៏ត្រូវបង្ហាញលេខ ERN ទាំងបីភាសាសម្រាប់ផ្នែកនោះ។ ដូច្នេះ អង្គជំនុំជម្រះនឹងផ្តល់ជូននូវពេលវេលាជាក់លាក់នៅក្នុងដំណើរការនីតិវិធី ដើម្បីឱ្យភាគីនោះ ដើម្បីផលប្រយោជន៍នៃប្រសិទ្ធផល អាចដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវឯកសារទាំងអស់ដែលមិនត្រូវបានទទួលយកទាក់ទិននឹងសក្ខីកម្មរបស់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីណាមួយ។ ការសួរដេញដោលផ្ទាល់មាត់ទាក់ទិននឹងការជំទាស់ទៅលើឯកសារ នឹងត្រូវអង្គជំនុំជម្រះកំណត់ពេលវេលាធ្វើឡើងផងដែរ ក្នុងករណីចាំបាច់។

*ការបង្ហាញឯកសារ និងសម្ភារៈសោតទស្សន៍*

បច្ចុប្បន្ននេះ ការបង្ហាញឯកសារ និងសម្ភារៈសោតទស្សន៍អាចធ្វើឡើងបានតែពីការិយាល័យក្រឡាបញ្ជី។ ដូច្នេះ ឯកសារ និងសម្ភារៈសោតទស្សន៍ដែលភាគីផ្សេងៗមានបំណងចង់បង្ហាញក្នុងសវនាការត្រូវជូនដំណឹង និងប្រគល់ជូនមន្ត្រីតុលាការឱ្យបានមុនពេលចាប់ផ្តើមសវនាការនោះ។ បច្ចុប្បន្ននេះ ផ្នែកគ្រប់គ្រងតុលាការកំពុងតែស្វែងរកទម្រង់បែបបទដែលអាចឱ្យភាគីទាំងអស់ បង្ហាញឯកសារពីអេក្រង់កំព្យូទ័ររបស់ខ្លួននៅក្នុងសាលសវនាការ។ ព័ត៌មានបច្ចុប្បន្នភាពស្តីពីបញ្ហានេះនឹងផ្តល់ជូនយ៉ាងឆាប់រហ័សតាមលទ្ធភាព។

*អញ្ញត្រកម្មបឋម*

ដូចដែលអង្គជំនុំជម្រះសាលាដំបូង បានបង្ហាញជូនពីមុនដែរ សេចក្តីសម្រេចតែមួយគត់ដែលអង្គជំនុំជម្រះមិនមានបំណងធ្វើឡើងនៅមុន ឬភ្លាមៗបន្ទាប់ពីចាប់ផ្តើមសវនាការ គឺពាក់ព័ន្ធនឹងអញ្ញត្រកម្មពី

សហមេធាវីរបស់ ខៀវ សំផន ទាក់ទិននឹងយុត្តាធិការលើបុគ្គល (E46)។ ដោយសារសេចក្តីសម្រេចចំពោះអញ្ញត្រកម្មនេះនាំឱ្យមានការវាយតម្លៃរួមគ្នាទៅលើអង្គហេតុ និងអង្គច្បាប់ ទើបសេចក្តីសម្រេចនេះនឹងត្រូវសម្រេចនៅក្នុងសវនាការដំណាក់លើកក្រោយ។

ខណៈដែលអង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ក្រុមមេធាវី អៀង សារី ទាក់ទិននឹងការលើកលែងទោស និងគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ កាលពីថ្ងៃទី ៣ ខែ វិច្ឆកា ឆ្នាំ ២០១១ (E51/15)នោះ សំណើរបស់ក្រុមមេធាវី អៀង សារី ស្នើសុំពន្យារការចាប់ផ្តើមសវនាការរហូតដល់មានសេចក្តីសម្រេចចុងក្រោយលើអញ្ញត្រកម្មនេះ (E135)កំពុងរង់ចាំការសម្រេច។ រហូតដល់ពេលនេះ អង្គជំនុំជម្រះបានផ្តល់អាទិភាព និងចេញសេចក្តីសម្រេចលើអញ្ញត្រកម្មទាំងអស់ជាប់ពាក់ព័ន្ធនឹងការរៀបចំសវនាការ ហើយអង្គជំនុំជម្រះបានយល់ឃើញថា សេចក្តីសម្រេចលើអញ្ញត្រកម្មដែលនៅសល់មួយចំនួនតូចនោះគឺមិនមែនជាឧបសគ្គដល់ការចាប់ផ្តើមសវនការលើអង្គសេចក្តីនៅក្នុងសំណុំរឿង ០០២ នៅថ្ងៃទី ២១ ខែ វិច្ឆកា ឆ្នាំ ២០០១ ឡើយ។ អង្គជំនុំជម្រះ មិនមែនបំណងពន្យារដំណើរការនីតិវិធី ក្នុងករណីដែលសេចក្តីសម្រេចណាមួយលើអញ្ញត្រកម្ម ត្រូវបានប្តឹងឧទ្ធរណ៍នៅអង្គជំនុំជម្រះសាលាកំពូលឡើយ។ នេះគឺជាការឆ្លើយតបផ្លូវការរបស់អង្គជំនុំជម្រះ ចំពោះលិខិតរបស់ក្រុមមេធាវីអៀង សារី ជូនមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ ចុះថ្ងៃទី ៤ ខែ វិច្ឆកា ឆ្នាំ ២០១១ ទាក់ទិននឹងព័ត៌មានពីអញ្ញត្រកម្មដែលនៅសេសសល់។

*សំណើរបស់សហព្រះរាជអាជ្ញា (E127) និងការឆ្លើយតបរបស់ក្រុមមេធាវី អៀង សារី (E127/1)*

បច្ចុប្បនេះ អង្គជំនុំជម្រះ មិនមានចម្លើយសាក្សីដែលបានលើកឡើងនៅក្នុងឯកសារខាងលើនេះឡើយ ហើយឥឡូវនេះកំពុងពិចារណាលើលទ្ធភាពជម្រើសផ្សេងៗដើម្បីទទួលបានចម្លើយសាក្សីទាំងនោះ។ អង្គជំនុំជម្រះនឹងចេញសេចក្តីណែនាំទាក់ទិននឹងសំណើនេះក្នុងចិរវេលាសមស្រប។ អង្គជំនុំជម្រះធ្វើការកត់សម្គាល់ឃើញថា គ្មានចម្លើយសាក្សីណាដែលបានលើកឡើងនៅក្នុងឯកសារខាងលើនេះមានប្រភពដើមពីសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងបញ្ជីស្តីពីសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់អង្គជំនុំជម្រះ ដែលត្រូវកោះហៅឱ្យផ្តល់សក្ខីកម្មនៅក្នុងសវនាការដំណាក់កាលដំបូងនេះឡើយ (ឧបសម្ពន្ធ ខ ឯកសារ E131/1.2)។

*សំណើឱ្យមានកិច្ចប្រជុំរៀបចំសវនាការ និងកិច្ចប្រជុំមិនផ្លូវការជាមួយមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់*

អនុស្សរណៈនេះ តាមលទ្ធភាពបានដោះស្រាយបញ្ហាទាំងអស់ដែលបានលើកឡើងដោយភាគីទាំងអស់ទាក់ទិននឹងសវនាការដំណាក់កាលដំបូង។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថាមិនចាំបាច់មានកិច្ចប្រជុំរៀបចំសវនាការថែមទៀតឡើយមុនពេលចាប់ផ្តើមសវនការនេះ។ ទោះបីយ៉ាងណា មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង នឹងរៀបចំកិច្ចប្រជុំមិនផ្លូវការសម្រាប់ភាគីទាំងអស់ថ្ងៃសុក្រ ទី ១៨ ខែ វិច្ឆកា ឆ្នាំ ២០១១ ពេលថ្ងៃត្រង់នៅបន្ទប់ ៤១៦ ដើម្បីដោះស្រាយបញ្ហាជាក់ស្តែងដែលនៅសេសសល់។ ដោយសារបញ្ហាទំហំបន្ទប់ប្រជុំ សូមស្នើភាគីនីមួយៗកំណត់ការចូលរួមរបស់ខ្លួននៅត្រឹមសមាជិកចូលរួមចំនួនពីរនាក់។ កិច្ចប្រជុំនឹងធ្វើឡើងជាភាសាអង់គ្លេស។

កិច្ចប្រជុំមិនផ្លូវការបន្ថែមទៀតជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់នឹងត្រូវកំណត់ពេលវេលាតាមករណីចាំបាច់។